# សិលាចារឹកនគរវត្តលេខ១២ K.៣០២

## ១- សេចក្តីទូទៅ

បណ្តុំសិលាចារឹកសម័យកណ្តាលនៅប្រាសាទអង្គរវត្ត ត្រូវអ្នកស្រាវជ្រាវបារាំងហៅថាជាសិលាចារឹកសម័យទំនើបនៅប្រាសាទអង្គរវត្ត (Inscriptions Mdernes d'Angkor សរសេរកាត់ជា IMA) ។ ឯមហាពិទូរ ឈឹម ក្រសេម ហៅថា សិលាចារឹកនគរវត្ត។ នៅទីនេះ យើងលើកយកនូវសិលាចារឹកមួយផ្ទាំង គឺសិលាចារឹកនគរវត្តលេខ១២ (IMA ១២, K.៣០២) ដែលចារនៅលើសសរប្រាសាទអង្គរវត្ត ត្រង់រូតព្រះពាន់។

សិលាចារឹកនេះបានចុះផ្សាយក្នុងសៀវភៅ សិលាចារឹកនគរវត្ត ដែលជាស្នាដៃរបស់មហាពិទូរ ឈឹម ក្រសេម[១] ត្រង់ទំព័រ៣១-៣២ និងលោកស្រីបណ្ឌិត ពៅ សាវរស[២] ចុះផ្សាយក្នុងព្រឹត្តិបត្រសាលាបារាំងចុងបូព៌ាប្រទេស (BEFEO)។ ខ្លឹមសារនៃសិលាចារឹកនេះគឺចារឹកអំពីក្រុមអ្នកធ្វើដំណើរធម្មយាត្រាទៅធ្វើបុណ្យនៅឯអង្គរវត្ត នាសតវត្សរ៍ទី១៧ ដោយឆ្លងកាត់ខ្យល់ព្យុះយ៉ាងលំបាកក្នុងទន្លេសាប ទម្រាំនឹងអាចបានជុំគ្នាធ្វើបុណ្យ។ ក្រោយពេលមកដល់ «មហានគរ» (តំបន់អង្គរ) និងបានជួបជុំកូនចៅញាតកាគ្រប់ហើយ អ្នកទាំងនោះចិត្តសទ្ធាជ្រះថ្លា បានរៀបចំពិធីបុណ្យដ៏ធំមួយនៅ «ព្រះពាន់» ។ ពួកគេបានកសាង ព្រះពុទ្ធរូបមាស ២អង្គ ប្រាក់ ៣អង្គ ថ្វាយទង់ធម្មជ ២ និងបាន បំបួសកូនប្រុស ២នាក់។ ក្នុងពិធីនោះ មានការនិមន្តព្រះសង្ឃ ជាពិសេសគឺ «ព្រះធម្មខិតមហាសង្ឃរាជ» ឱ្យសម្តែងធម៌ទេសនាធំៗ (អភិធម្មកណ្ឌ៣ និងមហាជាតក៍២) រួមជាមួយការថ្វាយគ្រឿងបូជាជាច្រើនដូចជា គ្រឿងបាយស្ងោ កម្រាលអាសនា ប្រាក់សមាទាន ភ្ញីកផ្ការ ភ្ញីកណ្តុរ និងមានការអុជកាំជ្រួចយ៉ាងឱឡារិក។

---

[១] ឈឹម ក្រសេម, សិលាចារឹកនគរវត្ត (១៩៣៦; Cedoreck, Centre de Documentation et de Recherche sur la Civilisation Khmère (CEDORECK), 1984).

[២] Saveros Lewitz, 'Inscriptions modernes d'Angkor 10, 11, 12, 13, 14, 15, 16a,16, et 16c', *Bulletin de l'École française d'Extrême-Orient* 59 (1972): 221–49, https://doi.org/10.3406/befeo.1972.5123.

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

តាមរយៈអត្ថបទនេះ ក៏អាចឲ្យយើងឃើញអំពីសំណេរនិងរចនាសម្ព័ន្ធឃ្លាខ្មែរនាសម័យកណ្ដាលផង។ បន្ថែមពីនេះ សិលាចារឹកនគរវត្តលេខ១២ ក៏បានបង្ហាញឲ្យយើងដឹងអំពីស្ថាននាមនានា ដូចជា «ទន្លេសាប» «កម្ពុជ» និង «បន្ទាយព្រេច» (ប្រហែលជាបន្ទាយពេជ្រ» ត្រូវនឹងរាំងឧដុង្គ)។

## ២- អត្ថបទដើមសរសេរជាអក្សរខ្មែរទំនើប

១- សព្ទម្ហស្តុសំម្រិត្តីតីរេក១៥៥០ សក្ហពេង់អ្នក្សត្រ

២- ខែហាបុស៦រោជថ្ងៃយសោរ៍ពារសារនាជិនុមថ្ងោ

៣- វពោវនាំមានន្ធថ្ងោវព្រិហ្មនាំបុសន្ធថ្ងោវសុក្ខនាំនេ

៤- ព្ទឥស្សធិង់អំប្បាលនេះមោគអំម្ធិយបណ្ឌាយព្រេផ្ល

៥- ធ្វង់ននលេហសាប្បឲ្យហាឲ្យលគកេប្បកកាប្បអាក

៦- ញាពនេព្យ្រច្ចមោគយោលក្ខណាចោវដោវញ៉ាញាត្តីកា

៧- នោវនាមហានគរនេះគ្រោពហោយនេព្យថ្ងោវពោវនាំមាន

៨- ន្ធថ្ងោវព្រិហ្មនាំបុសន្ធវថ្ងោវសុក្ខនាំនេព្ទន្ធថ្ងោវនន្ធថ្ងោវឪ

៩- ថ្ងោវគាមមេកែវមេស្រីយមេចិនជីហាសោមឥស្សអ្នកធិង់អំប្បា

១០- លនេះមានចិត្តសារទ្ធាថ្ងៃហាព្រះពុទ្ធរុប្បមាស្សអង្គ២ច្រាកអ

១១- ង្គ៣ទង់ជាម្ហធ្វជ្ជ២ប្បស្សក្ខណា២អ្នកហោយនេព្យថ្ងោវពោវ

១២- ឱយអាភនណានិមនព្រះអារិយ្យសយ័ទ្រង់ចិត្តបរសុទ្ធសិលតិ

១៣- វិយ្យាបុត្តស្វតធិព្ទមុនព្រះប្វរិត្តនោនាព្រះពណាកំព្វជ្ជប្វភាណាម្ទា

១៤- អ្នកព្រះធំម្ទចិត្តិមហាសំប្រែវ៉ាភជប្វពិតព្រះអង្គឃង់សំតែង់ធំ

១៥- នេស្សាន្ទាព្រះអម្ធិជម្ហកាន៣មហាជាតិ២អានិស័ទង់និស័ព្រះ

១៦- ចម្វង់ប្វននិស័ង្ហស្សហោយម្ទាគ្រើង់ចាយគ្រើង់ស្វាហាត្តុំភាលអា

១៧- ស្សនានិង់ច្រាកស្នាទានជាលិង់៨ម្ទាធំង់គាមច្រូចម្ទាជ្វីហាក័ប្រោរម្ទា

១៨- ជ្វីហាកន្ធរជ្វីហាស្វាយជ្វីហាធំង់បណ្ឌាយព្រះពិស្សស្វលោកកំព្វជ្ជ

១៩- ប្វភាណាវ្វង់ម្រែង់ភាក្សីសព្វឌីស្សសម្វទ្ធាយហោយនេព្វស្វរេច

២០- ចប្បធំនេស្សនានាថ្ងៃយអានិត្យបរប្វរហោង់

## ៣- សេចក្ដីសម្រួលជាអក្ខរាវិរុទ្ធបច្ចុប្បន្ន

១- សុភមស្តុសំរិទ្ធីតិរេក ១៥៥០ស័ក ពេញនក្សត្រ

២- ខែបុស្ស ៦រោច ថ្ងៃសៅរ៍ សារណាជំនុំថៅ

អត្ថបទដោយៈ ហ៊ុន ឈុនតេង

៣- ពៅ នាងមាន នូវថៅព្រហ្ម នាងបុស នូវថៅសុខ នាងទេ

៤- ព អស់(អ្នក)ទាំងអម្បាលនេះ មកអំពីបន្ទាយព្រេច

៥- ធ្វងទន្លេសាប ព្យុះខ្យល់កកេបកកាបអាប

៦- ឡាបទើបរួចមោកយល់កូនថៅផៅញាវញាតកា

៧- នៅនាមហានគរនេះគ្រប់ហើយទើបថៅពៅ នាងមាន

៨- នូវថៅព្រហ្ម នាងបុស នូវថៅសុខ នាងទេព នូវថៅនន្ទ ថៅឪ

៩- ថៅគាម មេកែវ មេស្រី មេចិន ជីសោម អស់អ្នកទាំងអម្បាល

១០- នេះមានចិត្តសទ្ធាធ្វើព្រះពុទ្ធរូបមាស២អង្គ ប្រាក់

១១- ៣អង្គ ទង់ធម្មជជ២ បំបួសកូន២នាក់ហើយ ទើបថៅពៅ

១២- ឲ្យអារទនានិមន្តព្រះអរិយសង្ឃទ្រង់ចតុប្បារិសុទ្ធសីល

១៣- ឥរិយាបថសូត្រទិព្វមន្តព្រះបរិត្តនៅនាព្រះពាន់កម្ពុជបុរាណមាន

១៤- អ្នកព្រះធម្មខិតមហាសង្ឃរាជបពិត្រព្រះអង្គឯងសម្ដែងធម៌

១៥- ទេសនាព្រះអភិធម្មកណ្ឌ៣ មហាជាតក៍២ អានិសង្សទង់ អានិសង្សព្រះ

១៦- ចម្លងបួន អានិសង្សផ្នួស ហើយមានគ្រឿងបាយ គ្រឿងស្លា កម្រាលអា

១៧- សនា និងប្រាក់សមាទានជា៨លឹង មានទាំងកាំជ្រួច មានភ្លើកផ្កាវ មាន

១៨- ភ្លើកណ្ដុរ ភ្លើស្វាយ ភ្លើទាំងបន្ទាយព្រះពិស្ណុលោកកម្ពុជ

១៩- បុរាណរុងរឿងរស្មីសព្វទិសសមុទាយហើយទើបស្រេច

២០- ចប់ធម៌ទេសនានាថ្ងៃអាទិត្យបរិបូរណ៍ហោង។

## ៤- សេចក្ដីសង្កេតនានា

### ៤.១- សេចក្ដីសង្កេតផ្នែកអក្ខរាវិរុទ្ធ

ដ្បិតតែមិនគោរពតាមជាតិសព្ទទាំងស្រុង ក៏សំណេរភាគច្រើនបន្តនិរន្តរភាពពីសម័យអង្គរ និងសរសេរផ្អែកលើសូរដែលមានភាពបត់បែនខ្ពស់។ ខាងក្រោមនេះជាសេចក្ដីសង្កេតខ្លះៗ៖

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

- ប្រើ «៉» ជំនួសដាក់នៅលើព្យញ្ជនៈឬព្យាង្គ ជំនួសឲ្យអក្សរ «ង»។

ឧ. នាំ៉ = នាង, សយ៉...។

- មិនមានរស្សសញ្ញា។

ឧ. ប្រាក = ប្រាក់, គ្រោព = គ្រប់។

- ប្រើ េី = ឿ។

ឧ. គ្រើង = គ្រឿង។

- មិនគោរពតាមជាតិសព្ទបាលីសំស្ក្រឹត។

ឧ. អម្ធិធម្ម = អភិធម្ម

សោវពារ (< សៅរវារ) = សៅរ៍ពារ

ទេស្សាន្ទា = ទេសនា។

- ប្រើព្យញ្ជនៈ «ហ» ខាងចុង។

ឧ. ថ្ងេហ = ថ្ងៃ, ផ្ទីហ = ភ្ទី...។

- ស្រៈ «ុ» និង «ូ» ប្រើជាមួយអក្សរ «រ» មានរូបរាងដូចជើងរ «្រ»។

## ៤.២- សេចក្តីសង្ខេតស្ថាននាម

### ក- ទន្លេសាប

ផ្អែកតាមទិន្នន័យនិរុត្តិសាស្ត្រ និងកំណត់ត្រាប្រវត្តិសាស្ត្រ វាក្យសព្ទដើមដែលប្រជាជនខ្មែរប្រើប្រាស់សម្រាប់សម្គាល់តំបន់ដីសើមដ៏ធំនៅកណ្តាលប្រទេសកម្ពុជា គឺពាក្យ «**ទន្លេសាប**» តែមួយគត់។ ផ្អែកតាមតឹងតាងលាយលក្ខណ៍អក្សរយ៉ាងរឹងមាំ ដែលគាំទ្រលើអំណះអំណាងនេះ ដែលមានចំណាស់ដែលរកឃើញ គឺយ៉ាងហោចណាស់នៅក្នុងសិលាចារឹកសម័យកណ្តាលនៅអង្គរវត្ត (នាសតវត្សទី១៧) ដូចជាសិលាចារឹកនគរវត្តលេខ១៦២នេះ ដែលបានចារឹកបញ្ជាក់យ៉ាងច្បាស់លាស់នូវការប្រើប្រាស់នាមសព្ទនេះ ដោយពុំមាន «បឹង» នៅខាងមុខឡើយ។ ឯកសារប្រវត្តិសាស្ត្រដទៃៗទៀតក្នុងសម័យកាលបន្តបន្ទាប់ ក៏បានរក្សាការប្រើប្រាស់ទម្រង់ដើមនេះផងដែរ។

តាមន័យនិងការវិវត្តនៃភាសា ពាក្យ «**ទន្លេ**» ក្នុងបរិបទខ្មែរបុរាណ មានអត្ថន័យស្មើនឹងពាក្យ «**សមុទ្រ**»។ ក្នុងផ្នត់គំនិតខ្មែរ ពាក្យ «**ទន្លេសាប**» មានន័យចំថា «**សមុទ្រទឹកសាប**»។ ការដាក់ឈ្មោះនេះ គឺផ្អែកទៅលើការសង្កេតផ្ទាល់នៃលក្ខណៈភូមិសាស្ត្រ និងទំហំផ្ទៃទឹកដែលមានវិសាលភាពធំធេងល្វឹងល្វើយ ប្រៀបបានទៅនឹងមហាសាគរ។

ដំណើរវិវត្តនៃវាក្យសព្ទនេះបានជួបប្រទះនឹងបាតុភូតទំនាក់ទំនងភាសា នាសម័យអាណានិគមបារាំង។ តាមរយៈរដ្ឋបាលអាណានិគម ភូមិសាស្ត្រនេះត្រូវបានគេហៅជាភាសាបារាំងថា **«Le Grand Lac»** (បឹងដ៏ធំ) ឬ **«Grands Lacs en Tonlé Sap»** (បឹងធំៗនៅទន្លេសាប)[៣]។ ឥទ្ធិពលនៃភាសាបរទេស និងការធ្វើមូលដ្ឋានីយកម្ម (Localization) ក្រោបរិបទបានធ្វើឱ្យមានការប្រែសម្រួលទម្រង់បរទេសចូលមកក្នុងភាសាខ្មែរទំនើប ដែលបណ្តាលឱ្យពលរដ្ឋខ្មែរជំនាន់ក្រោយចាប់ផ្តើមប្រើប្រាស់ពាក្យ «**បឹងទន្លេសាប**»។ ទោះជាយោងតាមលក្ខណៈភូមិសាស្ត្រ ភូគព្ភសាស្ត្រ ទីតាំងនោះមានលក្ខណៈជា «បឹង» ក្តី ក៏នៅក្នុងវប្បធម៌ខ្មែរយល់ថានោះគឺជា «ទន្លេ» ឬ «សមុទ្រ»។

ការលេចឡើងនូវពាក្យថ្មី **«បឹងទន្លេសាប»** នេះ ឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីភាពទីទៃគ្នានៃផ្នត់គំនិតវប្បធម៌ និងការកំណត់ឈ្មោះភូមិសាស្ត្ររវាងខ្មែរនិងបារាំង។ គួរឲ្យកត់សម្គាល់ថា តាមរយៈការវិវត្តនេះ អ្នកប្រើប្រាស់ភាសាខ្មែរបានទោរទន់ទៅតាមការប្រែសម្រួលរបស់បារាំង ដោយយកពាក្យ «បឹង» (Lac) មកដាក់បន្ថែមនៅខាងដើម «ទន្លេសាប» ដោយកំណត់នូវបញ្ញត្តិថ្មីថា «បឹងទន្លេសាប» គឺជាបឹងទឹកសាបធម្មជាតិដែលធំជាងគេបំផុតនៅតំបន់អាស៊ីអាគ្នេយ៍ដែលព័ទ្ធជុំវិញដោយខេត្ត៥គឺជាបឹងទឹកសាបធម្មជាតិដែលធំជាងគេបំផុតនៅតំបន់អាស៊ីអាគ្នេយ៍។ ឯ «ទន្លេសាប» វិញ គឺជាខ្សែទឹកឬដៃបឹងដែលភ្ជាប់គ្នាពីទន្លេមេគង្គទៅកាន់បឹងទន្លេសាប។

[៣] យោងតាមផែនទីបុរាណវិទ្យានៃប្រទេសកម្ពុជាសម័យបុរាណ របសលោក លុយណេត៍ ដឺ ឡាហ្សុងគីយែរ ឆ្នាំ១៩១១។ សូមមើលតាមរយៈ៖ https://cik.efeo.fr/wp-content/uploads/photo-gallery/Lunet_de_Lajonquiere_១៩១១.jpg។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

### ខ- ឈ្មោះប្រទេសកម្ពុជា

ប្រទេសកម្ពុជា មានឈ្មោះពីបុរាណមកថា «កម្ពុជ» ឬ «កម្ពុជទេស» ដែលក្នុងអត្ថបទសិលាចារឹកនេះសរសេរជា «កំពូជ្ជ» ហាក់ដូចជាមានអំណានជា [កំ-ពុច]។ ត្រង់នេះយើងអាចសង្កេតលើពាក្យកម្ចីពីសំស្រ្កឹតបាលី ដែលមានស្រៈខ្លី៣នៅខាងចុង គឺ អ ឥ និង ឧ ដែលមាន២ករណី គឺ ១- មិនអានស្រៈខ្លីនោះ និង ២- ប្តូរស្រៈខ្លីនោះជាស្រៈវែង គឺ អ ជា អា, ឥ ជា ឦ និង ឧ ជា ឩ ( > ឩវ)។ ករណីនេះ ពុំបរិយាយអំពីអក្ខរាវិរុទ្ធសម័យបច្ចុប្បន្ននោះទេ។សូមសង្កេតបញ្ជីពាក្យខាងក្រោម៖

| សំស្រ្កឹតបាលី | ជាខ្មែរបែបទី១ | ជាខ្មែរបែបទី២ | អក្ខរាវិរុទ្ធបច្ចុប្បន្ន |
|---|---|---|---|
| អាសន | អាសន៑ (អ.ថ. អាស) | អាស្នា | អាសនៈ |
| កុមារ | កុមារ (អ.ថ. កុម៉ា) | កុមារា | កុមារ/កុមារា |
| ឝាខ/សាខ | - | សាខា | សាខា |
| បទុម | បទុម (អ.ថ. ប៉ទុំ) | បទុមា | បទុម/បទុមា |
| ហេតុ | ហេតុ (អ.ថ. ហែត) | - | ហេតុ |
| សត្រុ | សត្រុ (សម័យបុរាណ) | សត្រូ > សត្រូវ | សត្រូវ |
| ឫតុ | - | រដូ > រដូវ | រដូវ |
| គុរុ | គុរុ (សម័យបុរាណ) | គ្រូ | គ្រូ |
| ពោធិ | ពោធិ៍ (អ.ថ. ពោ) | ពោធី | ពោធិ៍ |
| ប្រសិទ្ធិ | ប្រសិទ្ធិ (អ.ថ. ប្រសិត) | ប្រសិទ្ធី | ប្រសិទ្ធិ/ប្រសិទ្ធី |
| ឫទ្ធិ | ឫទ្ធិ (អ.ថ. រឹត) | ឫទ្ធី | ឫទ្ធិ/ឫទ្ធី |
| កីត៌ិ | កេរ្តិ៍ | - | កេរ្តិ៍ |

### គ- បន្ទាយព្រេច ឬ បន្ទាយពេជ្រ

នៅក្នុងសិលាចារឹកនេះ ក្រុមអ្នកធ្វើបុណ្យ គឺមានពីតំបន់ឈ្មោះ «បណ្ដាយព្រេជ្ជ» ដែលត្រូវនឹងពាក្យបច្ចុប្បន្នថា «បន្ទាយព្រេច» ដែលយើងពុំស្គាល់ប្រាកដថាត្រូវនឹងទីតាំង

បច្ចុប្បន្នណានោះទេ។ យ៉ាងនេះក្ដី ប្រសិនបើនោះជាសំណេរមានបញ្ហា យើងអាចគិតដល់ពាក្យមួយទៀតគឺ «បន្ទាយពេជ្រ» ដែលជាឈ្មោះនៃវាំងរាជធានីឧដុង្គ[4]។

## តារាងវាក្យសព្ទ

| សម័យកណ្ដាល | សម័យបច្ចុប្បន្ន | សម័យកណ្ដាល | សម័យបច្ចុប្បន្ន |
|---|---|---|---|
| សព្ទម្មស្ត | សុភមស្តុ | សក្ខ | ស័ក |
| រោង៍អ្នក្សត្រ | រោងនក្សត្រ | ខែហាបុស | ខែបុស្ស |
| ថ្ងេយ | ថ្ងៃ | សោរ៍ពារ | សៅរ៍(ពារ < វារ) |
| ជំនុម | ជំនុំ | ថ្ងោរ៍ | ថៅ |
| ឆាំ | នាង | សុក្ខ | សុខ |
| ទេព្ភ | ទេព | ទេព្វ | ទើប |
| អំប្បាល | អម្បាល | មោក | មក |
| អំម្ពិយ | អំពី | ព្រេជ្ជ | ព្រេច |
| ទនលេហាសាប្ប | ទន្លេសាប | ខ្យហាខ្យល | ព្យុះខ្យល់ |
| កកេបកកាប | កកេបកកាប | ស្វរេច | ស្រេច |
| អាភព្វាព | អាបឡាប | យោល | យល់ |
| រូប្ច | រូប | ផោរ៍ | ផៅ |
| ក្វូណ | កូន | ញាត្តិកា | ញាតកា |
| នោរ៍ | នៅ | គ្រោព | គ្រប់ |
| ហោយ | ហើយ | ស្រីយ | ស្រី |
| ដីហា | ដី | សារទ្ធា | សទ្ធា |
| ថ្ងេហា | ធ្វើ | ប្រាក | ប្រាក់ |
| មាស្ស | មាស | ធាម្មជ្ជជ្ជ | ធម្មជជ/ធម្មធ្វជ |

[4] នេះជាព័ត៌មានទទួលបានពី បណ្ឌិត ឡេង ស៊ីវ៉េង។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

| | | | |
|---|---|---|---|
| ប្បួស | បំបួស | អារិយ្យសយ៍ | អរិយសង្ឃ |
| អាភទណា | អារទនា | ទ្រង៑ | ទ្រង់ |
| ឆិមន | និមន្ត | ធំទេស្សាន្នា | ធម៌ទេសនា |
| ចិត្តបរសុទ្ធសិល | ចតុប្បារិសុទ្ធសីល | តិរិយ្យាបុត្ត | ឥរិយាបថ |
| ស្វតទិព្ទមុន | សូត្រទិព្វមន្ត | ប្វរិត្ត | បវិត្ត |
| កំព្វជ្ជប្វរាណា | កម្ពុជបុរាណ | ម្នា | មាន |
| មហាសំឃ្រ្យ៌ារាជ | មហាសង្ឃរាជ | ប្វពិត | បពិត្រ |
| សំតែង | សម្តែង | អភ្វិធម្មក | អភិធម្ម |
| អានិស័ | អានិសង្ស | ផ្ទស្ស | ផ្ទួស |
| គ្រើង៑ | គ្រឿង | កាមច្រ្វច | កាំជ្រួច |
| ក្តុំរាលអាស្សនា | កម្រាលអាសនា | ដ្វីហា | ភ្វី |
| ក៌ហ្រារ | កង្ហារ | កន្ទ្វរ | កណ្តុរ |
| ព្រះពិស្សស្នុលោក | ព្រះពិស្ណុលោក | រ្វង៑ទ្រែង៑ភាក្សី | រុងរឿងរស្មី |
| ឌីស្ស | ទិស | សម្វុទ្ទាយ | សមុទាយ |
| បរប្វរ | បរិបូរណ៍ | ចប្ប | ចប់ |

## បញ្ជីឯកសារ

Lewitz, Saveros. ‘Inscriptions modernes d’Angkor 10, 11, 12, 13, 14, 15, 16a,16, et 16c’. *Bulletin de l’École française d’Extrême-Orient* 59 (1972): 221–49. https://doi.org/10.3406/befeo.1972.5123.

ឈឹម ក្រសេម. *សិលាចារឹកនគរវត្ត*. ១៩៣៦. Cedoreck. Centre de Documentation et de Recherche sur la Civilisation Khmère (CEDORECK), ១៩៨៤.

អត្ថបទដោយៈ ហ៊ុន ឈុនតេង

# បញ្ជីរូបភាព



K 302 **IMA 12** Imprint sheet no./លេខផ្ទិត: 69
Photograph no./លេខរូបថត: 69

សំណៅផ្តិតសិលាចារឹកនគរវត្តលេខ១២ (ប្រភព៖ APSARA & CKS)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង




ទីតាំងសិលាចារឹកនគរវត្តលេខ១២ (ប្រភព៖ APSARA & CKS)




អត្ថបទដោយ៖ ហ៊ុន ឈុនតេង